រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

030KH01A-01

សេចក្តីបង្គាប់ទាំងប្រាំពីរ
របស់ព្រះយេស៊ូគ្រីស្ត

សំរាប់ពួកសាវ័ករបស់ព្រះអង្គ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៣០

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

សូមទូលសូមអោយព្រះជាម្ចាស់ជួយអ្នក អោយអាចប្រតិបត្តិតាម
និងបង្រៀនសេចក្តីបង្គាប់ជាគ្រឹះរបស់ព្រះយេស៊ូ ។

ព្រះអម្ចាស់យេស៊ូប្រាប់យើងថា :

*«ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក
ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេឱ្យប្រតិបត្តិតាមសេចក្តី
ទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា »* ។

(ម៉ាថាយ ២៨:១៩-២០)



កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ព្រះអម្ចាស់យេស៊ូគ្រីស្តពន្យល់ពីរបៀបបង្កើតសាវ័ក នៅក្នុង ម៉ាថាយ ២៨:១៩-២០ ។ យើងធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី និងបង្រៀនពួកគេអោយចេះប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលព្រះអង្គបានបង្គាប់ដល់យើង ។

តើ "សេចក្តីបង្គាប់ទាំងអស់នោះ" គឺអ្វីខ្លះ ?

នៅក្នុងកូនសៀវភៅនេះ យើងនឹងទន្ទេញ និងរៀន ដោយសង្ខេបអំពីសេចក្តីបង្គាប់សំខាន់ៗទាំងប្រាំពីររបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត។



នៅពេលដែលអ្នកបានទន្ទេញសេចក្តីបង្គាប់ទាំងនេះចាំហើយ សូមសិក្សាសេចក្តីបង្គាប់ទាំងប្រាំពីរនេះម្តងមួយៗ ។

☐ កែប្រែចិត្តគំនិត និង ទទួលជឿ ។
(ម៉ាកុស ១:១៥)

☐ ទទួលពិធីជ្រមុជទឹក ។
(ម៉ាថាយ ២៨:១៩)

☐ ស្រឡាញ់ព្រះជាម្ចាស់ និង មនុស្សឯទៀត ។
(ម៉ាថាយ ២២:៣៧-៤០)

☐ អានព្រះបន្ទូលព្រះជាម្ចាស់ ទុកជាចំណីអាហារខាងព្រលឹង-វិញ្ញាណ និង អធិស្ឋានជារៀងរាល់ថៃ ។
(ម៉ាថាយ ៤:៤, ៦:៥-១៣)

☐ ជួបជុំគ្នាធ្វើពិធីកាច់នំប៉័ង ។
(ម៉ាថាយ ២៦:២៦-២៨)

☐ ចែកចាយ និង ថ្វាយដង្វាយ ។
(ម៉ាថាយ ៦:១៩-២១)

☐ បង្កើតសាវ័ក ។
(ម៉ាថាយ ២៨:១៨-២០)

- នៅពេលដែលក្រុមថ្មីមួយ ប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងប្រាំពីរនេះ ក្រុមនោះជាក្រុមជំនុំមួយហើយ ។

នេះជាអំណរមួយហើយ !



© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងប្រាំពីររបស់ព្រះគ្រីស្តនេះ ជាមួយក្រុមជំនុំរបស់អ្នក ! អធិស្ឋានទូលសូមឱ្យព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឱ្យអ្នកមានសេចក្តីស្រឡាញ់ និងឫទ្ធានុភាពដើម្បីអាចប្រតិបត្តិតាមសេចក្តីបង្គាប់ ដោយខ្លួនឯងជាមុនសិន បន្ទាប់មក ទើបបង្រៀនសេចក្តីបង្គាប់នេះទៅអ្នកឯទៀត ។

  (បើអ្នកត្រូវការជំបូន្មាន ឬជំនួយ សូមប្រាប់គ្រូបង្ហាត់របស់អ្នក) ។

- សេចក្តីបង្គាប់របស់ព្រះគ្រីស្តទាំងប្រាំពីរនេះ ជាគ្រឹះរឹងមាំ ។ យើងត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងនេះ ខ្លាំងជាងបទបញ្ញត្តិផ្សេងៗទៀតរបស់និកាយ និងមតិយោបល់របស់យើង ។ សេចក្តីបង្គាប់ទាំងនេះជាព្រះបន្ទូលរបស់ព្រះយេស៊ូដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយព្រះអង្គបានបង្គាប់យើងអោយប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងនេះ និងបង្រៀនអ្នកឯទៀតអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងនេះដែរ ។

កែប្រែចិត្តគំនិត និង ទទួលជឿ

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«ពេលកំណត់មកដល់ហើយ រីងព្រះរាជ្យរបស់ព្រះជាម្ចាស់ ក៏មកជិតបង្កើយដែរ ។ ចូរនាំគ្នាកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ ! »* ។ ការកែប្រែចិត្តគំនិតដ៏ពិតប្រាកដ និងទទួលជំនឿ ត្រូវតែមានព្រមគ្នាជានិច្ច ។ អ្នកមិនអាចមានមួយ អត់មួយបានទេ ។

(ម៉ាកុស ១:១៥)

ព្រះគ្រីស្ត



បាប

កែប្រែចិត្តគំនិត គឺបែរចេញពីបាប ទៅប្រតិបត្តិតាមព្រះគ្រីស្ត ។

យើងលះបង់ចោលអំពើបាបរបស់យើង ដើម្បីដើរតាមព្រះគ្រីស្ត ។ នៅពេលដែលយើងកែប្រែចិត្តគំនិត ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់ក្នុងចិត្តរបស់យើង ដោយសារយើងជឿ ។ ជំនឿលើព្រះគ្រីស្តមិនមែនគ្រាន់តែសង្គ្រោះយើងប៉ុណ្ណោះទេ តែជួយយើងអោយអាចរស់នៅតាមព្រះហឫទ័យព្រះជាម្ចាស់ និង បំរើព្រះអង្គដោយចិត្តស្មោះត្រង់ទៀតផង ។ យើងត្រូវប្តេជ្ញាចិត្តចុះចូលចំពោះការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីអោយយើងមានជីវិតបរិសុទ្ធជាប់ជានិច្ច ។

ទទួលពិធីជ្រមុជទឹក

«ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ » ។

(ម៉ាថាយ ២៨:១៩)



៨- បង្កើតសាវ័កមានន័យថា :

- ☐ ផ្សាយដំណឹងល្អទៅពួកអ្នកមិនទាន់ជឿ ។
- ☐ បង្រៀនពួកអ្នកជឿថ្មីឱ្យចេះប្រតិបត្តិតាមព្រះគ្រីស្ត ។
- ☐ ឃ្វាលអ្នកជឿ ដោយណែនាំអោយពួកគេជឿរឹកឡើងក្នុងព្រះគ្រីស្ត ។
- ☐ បង្ហាត់បង្រៀនអ្នកជឿអោយធ្វើជាគ្រូគង្វាល អ្នកដឹកនាំ និងគ្រីស្តទូត ។
- ☐ សេចក្តីទាំងប៉ុន្មានខាងលើនេះ ។

© Project WorldReach © SEAN

- បើសិនជាយើងមិនទទួលពិធីជ្រមុជទឹក នោះយើងមិនមែនជាសាវ័កដែលចេះប្រតិបត្តិតាមព្រះយេស៊ូគ្រីស្តទេ ។
- ពិធីជ្រមុជទឹកបញ្ជាក់ថា យើងបានកែប្រែចិត្តគំនិតចេញពីអំពើបាប និងថាយើងជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តរួចហើយ ។
- នៅក្នុងព្រះគម្ពីរ ពួកអ្នកជឿថ្មីទទួលពិធីជ្រមុជទឹកភ្លាមៗ ។ នៅពេលខ្លះ ក្រុមគ្រួសារទាំងមូលទទួលជឿព្រះយេស៊ូទាំងអស់គ្នា ហើយបានទទួលពិធីជ្រមុជទឹកព្រមជាមួយគ្នាដែរ ។
- ពិធីជ្រមុជទឹកជាជំហានដំបូងសំរាប់សាវ័កថ្មី ។ រ៉ូម ៦:១-១២ បង្ហាញថាយើងស្លាប់ពីអំពើបាបជាមួយព្រះគ្រីស្ត និងរស់ឡើងវិញជាមួយព្រះអង្គ ដើម្បីមានជីវិតថ្មី និងបរិសុទ្ធ។

កំណត់ចំណាំ : ក្រុមជំនុំទាំងឡាយមានរបៀបធ្វើពិធីជ្រមុជទឹកផ្សេងៗគ្នា ។ ត្រូវជឹងអោយច្បាស់អំពីរបៀបធ្វើពិធីជ្រមុជទឹករបស់ក្រុមជំនុំអ្នក ។

៦- យើងត្រូវអធិស្ឋានដោយ :

- ☐ សូត្រឃ្លាដែលយើងទន្ទេញចាំច្រើនដង ។
- ☐ ជំនឿ និងសេចក្តីស្រឡាញ់ ដូចជាកូននិយាយទៅរកឪពុកខ្លួន ។

៧- របៀបថ្វាយបង្គំ ដែលយើងអាចគោរពបូជាព្រះគ្រីស្តយ៉ាងសកម្ម និងយ៉ាងស្និទ្ធស្នាលបំផុតបាន គឺ :

- ☐ មានពួកអ្នកភ្លេង និងពួកអ្នកច្រៀង ដែលពូកែបំផុតនៅក្នុងក្រុមជំនុំរបស់អ្នក ។
- ☐ ពិធីកាច់នំបុ័ង ដើម្បីរំលឹកពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ។

ស្រឡាញ់ព្រះជាម្ចាស់ និង មនុស្សឯទៀត

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក អោយអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញាហ្នឹងហើយជាវិន័យទីមួយ ដែលសំខាន់ជាងគេបំផុត »* ។

(ម៉ាថាយ ២២:៣៧-៤០)

- ការស្រឡាញ់ព្រះជាម្ចាស់អោយអស់ពីចិត្ត មិនមែនគ្រាន់តែជាមនោសញ្ចេតនាប៉ុណ្ណោះទេ តែជាការប្តេជ្ញាចិត្តទុកព្រះអង្គជាទី១ ក្នុងជីវិតរបស់យើង ។ *«ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ »* ។
(យ៉ូហាន ១៤:១៥)

- មានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ នាំអោយយើងចេះស្រឡាញ់មនុស្សឯទៀត ។ *«អ្នកណាស្រឡាញ់ព្រះជាម្ចាស់ អ្នកនោះក៏ត្រូវស្រឡាញ់បងប្អូនដែរ »* ។
(១ យ៉ូហាន ៤:២១)

- ស្រឡាញ់អ្នកជិតខាងរបស់អ្នក គឺស្រឡាញ់ខ្មាំងសត្រូវរបស់អ្នកដែរ ។
(ម៉ាថាយ ៥:៤៤)

៣- នៅក្នុងសម្ពន្ធមេត្រីថ្មី ទទួលពិធីជ្រមុជទឹក គឺជា :

☐ ការទទួលសញ្ញាប័ត្រ ក្រោយដែលបានរៀនចប់វគ្គសិក្សា អំពីគោលជំនឿព្រះគម្ពីរមួយ ។

☐ ហេតុការមួយ ដែលតំណាងការស្លាប់របស់យើងរួមជាមួយព្រះគ្រីស្ត ពីអំពើបាប និងការរស់ឡើងវិញរបស់យើង ដើម្បីមានជីវិតថ្មីរួមជាមួយព្រះអង្គ ។

៤- តើយើងអាចទទួលឫទ្ធានុភាព ដែលនាំអោយអាចស្រឡាញ់សត្រូវរបស់យើងបាន ពីអ្នកណា ?

☐ មេរៀនអំពីសុជីវធម៌ (របៀបរបបល្អ) ។

☐ ព្រះជាម្ចាស់ ។

៥- ព្រះជាម្ចាស់ចង់អោយយើងថ្វាយដង្វាយ ដោយសារ :

☐ យើងភ័យខ្លាចព្រះអង្គដាក់ទោស បើសិនជាយើងអាត្មានិយម ។

☐ យើងស្រឡាញ់ និងចង់អរព្រះគុណព្រះជាម្ចាស់ចំពោះកិច្ចការដែលព្រះយេស៊ូបានធ្វើសំរាប់យើងរាល់គ្នា ។

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- សូមសរសេរសេចក្តីបង្គាប់សំខាន់ៗ ទាំងប្រាំពីររបស់ព្រះ-អម្ចាស់យេស៊ូ ដោយមិនបាច់មើល :

_____

_____

_____

_____

_____

_____

_____

២- នៅក្នុងសម្ពន្ធមេត្រីថ្មី ពាក្យ « កែប្រែចិត្តគំនិត » មានន័យថា :

☐ ការកែប្រែជារៀងរហូត ។

☐ ការសោកស្តាយមួយភ្លែតពីអំពើអ្វីមួយ ដែលយើងបានធ្វើខុស ។

- ស្រឡាញ់ខ្មាំងសត្រូវ គឺជួយសត្រូវ នៅពេលដែលអ្នកនោះជួបការខ្វះខាត ។
(លូកា ១០:២៥-៣៧)

- សេចក្តីស្រឡាញ់ប្រភេទនេះ មិនមែនកើតមាននៅនឹងយើងដោយឯកឯងនោះទេ « *សេចក្តីស្រឡាញ់កើតមកពីព្រះជាម្ចាស់* » ។
(១ យ៉ូហាន ៤:៧)

- សេចក្តីស្រឡាញ់ដែលកើតពីព្រះជាម្ចាស់ ជាផលផ្លែរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់ក្នុងយើង ។ ព្រះវិញ្ញាណ-ដ៏វិសុទ្ធបណ្តាលអោយយើងស្រឡាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងរបស់យើង ។ « *រីឯផលដែលកើតមកពីព្រះវិញ្ញាណវិញ គឺសេចក្តីស្រឡាញ់...* » ។
(កាឡាទី ៥:២២)



អានព្រះបន្ទូលព្រះជាម្ចាស់ និង អធិស្ឋានជារៀងរាល់ថៃ

ព្រះយេស៊ូមានព្រះបន្ទូលតបវិញថា÷ *«ក្នុងគម្ពីរមានចែងថា "មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញមកពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ" »* ។ (ម៉ាថាយ ៤:៤)

«.....កាលណាអ្នករាល់គ្នាអធិស្ឋាន កុំធ្វើដូចពួកអ្នកមានពុតដែលចូលចិត្តឈរអធិស្ឋាន...ដើម្បីអោយមនុស្សម្នាឃើញនោះឡើយ...កាលណាអ្នកអធិស្ឋាន ត្រូវចូលទៅក្នុងបន្ទប់បិទទ្វារឱ្យជិត ហើយទូលទៅកាន់ព្រះបិតារបស់អ្នក ដែលគង់នៅក្នុងទីសាត់កំបាំង ។ ព្រះបិតារបស់អ្នកដែលទតឃើញនៅក្នុងទីសាត់កំបាំង ទ្រង់នឹងប្រទានរង្វាន់មកអ្នកជាពុំខាន » ។ (ម៉ាថាយ ៦:៥)

«ពេលទូលទៅព្រះបិតា កុំពោលពាក្យច្រំដែលៗ ឥតប្រយោជន៍ដូចសាសន៍ដទៃនោះឡើយ ។ គេនឹកស្មានថា បើពោលពាក្យយ៉ាងច្រើនដូច្នេះ ព្រះរបស់គេនឹងស្តាប់គេ ។ កុំធ្វើដូចគេឡើយ ដ្បិតព្រះបិតារបស់អ្នករាល់គ្នាជ្រាបនូវអ្វីៗ ដែលអ្នករាល់គ្នាត្រូវការ មុនអ្នករាល់គ្នាទូលសូមព្រះអង្គទៅទៀត »។ (ម៉ាថាយ ៦:៧-៨)

- បន្ទាប់មក ជួយពួកអ្នកដែលកែប្រែចិត្តគំនិត និងទទួលជឿ ដោយបង្រៀនពួកគេអោយចេះធ្វើតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូ ដូចដែលអ្នកខ្លួនឯងកំពុងធ្វើពេលនេះដែរ ។ ធ្វើដូចនេះ គឺអ្នកអាចជួយពួកគេអោយក្លាយជាចាស់ទុំខាងព្រលឹងវិញ្ញាណ និងបំពេញកិច្ចការបំរើព្រះជាម្ចាស់របស់ពួកគេបាន ហើយលទ្ធផល គឺព្រះរាជ្យរបស់ព្រះគ្រីស្តនឹងរីកធំឡើង ។

ចំណុចមួយទៀតនៃការបង្កើតសាវ័ក គឺបង្ហាត់បង្រៀនគ្រូគង្វាល និងគ្រីស្តទូតអោយទៅផ្សាយដំណឹងល្អដល់« ជាតិសាសន៍» នានា ។

ប្រហែលជាថ្ងៃណាមួយ ព្រះជាម្ចាស់ក៏អាចត្រាស់ហៅអ្នកអោយធ្វើជាគ្រូគង្វាល ឬ គ្រីស្តទូតដែរ មែនទេ ? _____



តើអ្នកធ្វើតាមសេចក្តីបង្គាប់ទាំងអស់នេះទេ ?

បង្កើតសាវ័ក

ព្រះយេស៊ូយាងចូលមកជិតគេ ហើយមានព្រះបន្ទូលថា៖ «*ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេឱ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក* » ។

(ម៉ាថាយ ២៨:១៨-២០)

- ការបង្កើតសាវ័ក រួមមានការផ្សាយដំណឹងល្អ និង ការបង្រៀន ដែលមានច្រើនផ្នែក ។
- អ្នកគួរចាប់ផ្តើម ដោយផ្សាយដំណឹងល្អប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកដែលមិនទាន់ជឿ ។

ក្នុងម៉ាថាយ ៦:៩-១៣ ព្រះយេស៊ូមានព្រះបន្ទូលថា៖« *អ្នករាល់គ្នាត្រូវទូលព្រះអង្គដូចតទៅ* » :

"ឱព្រះបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !
សូមសំដែងព្រះបារមីអោយមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ ។
សូមអោយព្រះរាជ្យព្រះអង្គបានមកដល់ ។
សូមអោយព្រះហឫទ័យរបស់ព្រះអង្គ
បានសំរេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ ។
សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ ។
សូមអត់ទោសអោយយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស
អោយអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ ។
សូមកុំបណ្តោយអោយយើងខ្ញុំចាញ់ការល្បួងឡើយ
តែសូមរំដោះយើងខ្ញុំឱ្យរួចពីមារកំណាច » ។



ព្រះជាម្ចាស់ចង់មានទំនាក់ទំនងផ្ទាល់ជាមួយនឹងអ្នក :

- ព្រះជាម្ចាស់ចង់មានព្រះបន្ទូលមកកាន់អ្នក តាមរយៈព្រះ-បន្ទូលរបស់ព្រះអង្គ គឺព្រះគម្ពីរ ។ សូមអានព្រះគម្ពីរជារៀងរាល់ថ្ងៃ ដើម្បីឱ្យព្រះវិញ្ញាណដ៏វិសុទ្ធណែនាំអ្នកអោយរស់តាមព្រះហឫទ័យរបស់ព្រះអង្គ ដោយសេចក្តីស្រឡាញ់។
- ព្រះជាម្ចាស់ចង់អោយអ្នកនិយាយទូលទៅព្រះអង្គ ដោយការអធិស្ឋាន ។
- មិនចាំបាច់និយាយពាក្យក្បោះក្បាយ ឬ ទន្ទេញឃ្លាដើម្បីសូត្រទេ ។ ព្រះគ្រីស្តមិនពេញព្រះទ័យនឹងការនិយាយដដែលៗ គ្មានបានការនោះទេ ។ សូមនិយាយតាមធម្មតា និងដោយគោរពទៅកាន់ព្រះបិតារបស់អ្នក ដែលគង់នៅស្ថានបរមសុខចុះ ។
- អ្នកអាចអធិស្ឋានលុតជង្គង់ ក្រាប អង្គុយ ឬឈរក៏បាន ។ ព្រះជាម្ចាស់មិនសូវទតមើលកាយវិការប៉ុន្មានទេ តែព្រះអង្គទតមើលទឹកចិត្តខ្លាំងជាង ។

- ដង្វាយស្ម័គ្រចិត្ត និងដង្វាយដប់ភាគរយ សំរាប់ជួយបងប្អូនក្នុងព្រះគ្រីស្តដែលខ្វះខាត សំរាប់ផ្គត់ផ្គង់គ្រូគង្វាល សំរាប់ផ្គត់ផ្គង់ការងាររបស់គ្រីស្តទូតនៅប្រទេសក្រៅ និងសំរាប់ចំណាយគ្រប់យ៉ាងដែលទាក់ទងនឹងការងាររបស់ព្រះអង្គ ។



- ការដាក់ដង្វាយ ជាផ្នែកមួយនៃការថ្វាយបង្គំព្រះជាម្ចាស់ ។
- ព្រះជាម្ចាស់ទុកព្រះពរសំរាប់យើងនៅស្ថានបរមសុខ ស្របតាមដង្វាយដែលយើងថ្វាយព្រះអង្គនៅលើផែនដី (លូកា ១២:៣៣) ។
- អ្នកក្រដែលថ្វាយតិច តែដោយធ្វើពលិកម្ម ដោយសេចក្តីស្រឡាញ់ និង ដោយជំនឿ នោះនឹងទទួលរង្វាន់នៅស្ថានបរមសុខ ធំលើសពួកអ្នកដែលដាក់ដង្វាយច្រើន តែយកពីអ្វីដែលគេនៅសល់ហើយ (ម៉ាកុស ១២:៤៣-៤៤) ។
- ព្រះជាម្ចាស់សព្វព្រះទ័យនឹងអ្នកដែលថ្វាយដង្វាយ ដោយអំណរ (២ កូរិនថូស ៩:៧) ។ អ្នកមិនត្រូវដាក់ដង្វាយដោយនឹកស្តាយ ឬ ទើសទំលឡើយ ។
- នៅក្នុងសម្ពន្ធមេត្រីថ្មី គ្មានក្រិត្យវិន័យអំពីការដាក់ដង្វាយដប់ភាគរយទេ ដូចនេះ បើសិនជាអ្នកដាក់ដង្វាយដប់ភាគរយ គឺអ្នកត្រូវដាក់ដោយសារមានចិត្តស្រឡាញ់ ។

ជួបជុំគ្នាធ្វើពិធីកាច់នំបុ័ង

នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំបុ័ងមកកាន់ ។ ព្រះអង្គសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានអោយពួកសាវ័ក ដោយមានព្រះបន្ទូលថា÷ *«នេះជារូបកាយខ្ញុំ សុំយកពិសាចុះ »។ បន្ទាប់មក ព្រះអង្គយកពែងមកកាន់អរព្រះគុណព្រះជាម្ចាស់ រួចប្រទានអោយពួកសាវ័ក ទាំងមានព្រះបន្ទូលថា÷ «សុំយកពិសាទាំងអស់គ្នាចុះ នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រីដែលត្រូវបង្ហូរ ដើម្បីលើកលែងទោសមនុស្សទាំងអស់អោយរួចពីបាប »* ។

(ម៉ាថាយ ២៦:២៦-២៨)



- យើងត្រូវធ្វើពិធីកាច់នំប៉័ង ដើម្បីរំលឹកពីព្រះយេស៊ូ និងប្រកាសអំពីការសុគតរបស់ព្រះយេស៊ូ រហូតដល់ព្រះអង្គយាងមកវិញ (១ កូរិនថូស ១១:២៦) ។
- ព្រះយេស៊ូមានបន្ទូលអំពីនំប៉័ងដែលព្រះអង្គកាច់ថា÷ *«នេះជារូបកាយរបស់ខ្ញុំ»* ។ នៅពេលដែលយើងពិសានំប៉័ងនោះ យើងត្រូវនឹកឃើញពីរូបកាយរបស់ព្រះអង្គ ដែលត្រូវខ្ទេចខ្ទាំ ដើម្បីយើងរាល់គ្នា (១ កូរិនថូស ១០:១៦) ។
- ព្រះយេស៊ូមានបន្ទូលពីទឹកទំពាំងបាយជូរថា÷ *«នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រី»* ។ នៅពេលដែលយើងទទួលទានទឹកទំពាំងបាយជូរ យើងត្រូវនឹកឃើញពីព្រះលោហិតរបស់ព្រះអង្គដែលត្រូវហូរ ដើម្បីអោយព្រះ-ជាម្ចាស់លើកលែងទោសអំពើបាបរបស់យើង ។
- អ្វីៗទាំងអស់ដែលយើងធ្វើក្នុងពិធីកាច់នំប៉័ង បញ្ជាក់ថាព្រះ-អង្គគង់ជាមួយយើង លើកលែងទោសឱ្យយើង និងប្រទានបុទ្ធានុភាពដល់យើង ។ នៅពេលដែលយើងធ្វើពិធីកាច់នំប៉័ង គឺយើងរក្សាទំនាក់ទំនងរបស់យើងជាមួយព្រះគ្រីស្ត និងប្រជារាស្ត្រព្រះអង្គអោយនៅស្ថិតស្ថេរ (១ កូរិនថូស ១០:១៦-១៧) ។

កំណត់ចំណាំ : ក្រុមជំនុំទាំងឡាយមានរបៀបធ្វើពិធីកាច់នំប៉័ងផ្សេងៗគ្នា ។ សូមដឹងអោយច្បាស់អំពីរបៀបធ្វើពិធីកាច់នំប៉័ងរបស់ក្រុមជំនុំរបស់អ្នក ។

ចែកចាយ និង ថ្វាយដង្វាយ

«ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ» ។

(លូកា ៦:៣៨)

«កុំសន្សំទ្រព្យសម្បត្តិទុកសំរាប់ខ្លួន នៅលើផែនដី ជាកន្លែងដែលមានកណ្តៀរ និងច្រែះស៊ី ជាកន្លែងដែលមានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់អោយសោះ ។ ចូរប្រមូលទ្រព្យសម្បត្តិទុកនៅស្ថានបរមសុខវិញ ជាស្ថានដែលគ្មានកណ្តៀរ និងច្រែះស៊ី ជាស្ថាន ដែលគ្មានចោរទម្លាយជញ្ជាំងចូលមកលួចឡើយ ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ» ។

(ម៉ាថាយ ៦:១៩-២១)